AMS

# បណ្ដាសាជូនតា

**បណ្ដាសា** គឺជាពាក្យផ្ដន្ទា ជេរប្រទេច សំបូងសង្រ្វង់ឲ្យគេវិនាសហិនហោច។[១] ក្នុងសម័យបុរាណគេសរសេរថា "**សាប ឬសាបថ**"។[២] ពាក្យនេះបច្ចុប្បន្នសរសេរថា "**ស្បថ**" មានន័យថា ប្រកាសសេចក្ដីពិតត្រង់។[៣] នៅក្នុងសិលាចារឹក ពាក្យបណ្ដាសាតែងលេចឡើងអមជាមួយពាក្យឱ្យពរ ប៉ុន្ដែអត្ថបទនេះនឹងលើកមកបង្ហាញតែអំពីពាក្យបណ្ដាសាប៉ុណ្ណោះ។ ពាក្យបណ្ដាសា បានលេចឡើងក្នុងសិលាចារឹកខ្មែរតាំងពីសម័យមុនអង្គរ។ សិលាចារឹកដែលចាស់ជាងគេ គឺសិលាចារឹកទួលគោកព្រះ ចុះកាលបរិច្ឆេទឆ្នាំ៥៧៩សក ត្រូវនឹងឆ្នាំ៦៥៧នៃគ្រិស្ដសករាជ។[៤]

តើហេតុអ្វីបានជាមានការដាក់បណ្ដាសាក្នុងសិលាចារឹកខ្មែរ?

ពាក្យបណ្ដាសា បានលេចឡើងនៅភាគខាងចុងនៃអត្ថបទសិលាចារឹក ដែលភាគច្រើននិយាយទាក់ទងនឹងការស្ថាបនាប្រាសាទ ការធ្វើបដិមា និងការថ្វាយដង្វាយផ្សេងៗទៅដល់ទេព ឬប្រាសាទ ដោយព្រះមហាក្សត្រ ព្រះគ្រូ និងមន្ត្រីជាដើម។ គេដាក់បណ្ដាសាទៅដល់មនុស្សណាម្នាក់ ឬក្រុមណាមួយដែលបំផ្លាញ "**បុណ្យ**" ឬ "**ធម៌**" ឬពាក្យដែលកាន់តែសម័ញ្ញទៀតនោះហៅថា "**សមិទ្ធផល**" ដែលគេបានធ្វើឱ្យធ្លាក់នរក រងការកាត់ទោសពីសំណាក់ព្រះយម និងចិត្រាគុប្ត ( អ្នកកាន់បញ្ជីកម្មរបស់មនុស្ស) (រូបលេខ១)។

ពាក្យបណ្ដាសា មានច្រើនបែបច្រើនទម្រង់ ហើយក៏គួរឱ្យភ័យខ្លាចបំផុតដែរ។ ឧទាហរណ៍សិលាចារឹក គុកប្រដាក និយាយពីការស្ថាបនាប្រាសាទ និងព្រះសិវលិង្គ ព្រមទាំងបញ្ជាក់ជាចុងក្រោយថា "នេះជាបណ្ដាសារបស់ព្រាហ្មណ៍ អាចារ្យ បណ្ឌិត" ទៅដល់អ្នកដែលលោភយកបុណ្យនេះឲ្យធ្លាក់ទៅ នរករៅរវ (ដែលល្វរ ដែលស្រែក)[៥] និងនរក

---

[១] ជួន ណាត (១៩៦៧-១៩៦៨)

[២] STCHOUPAK, N. NITTI et RENOU (1959:327)

[៣] ជួន ណាត (១៩៦៧-១៩៦៨)

[៤] មាស សុភាព (២០០៧: ៣១)

[៥] Coèdes Geoge (1973:29)

អត្ថបទដោយ៖ មាស សុភាព

*ផ្សេងៗទៀតជាមួយនឹងបុព្វបុរសរបស់ខ្លួន។ ដោយឡែកសិលាចារឹក គុកព្រីងជ្រុំ K.៩២ ផ្នែក C បន្ទាត់ទី២៣ និង២៤ គេដាក់បណ្ដាសាឱ្យមនុស្សដែលមានកំហុសនោះធ្លាក់ចុះទៅក្នុងរណ្ដៅអវចី (គ្មានទីជ្រកពួន[៦] មានរយៈពេល៤០០០ឆ្នាំនរក ដែលមួយថ្ងៃមួយយប់ស្មើនឹង៥៧៦ ០០០ ០០០ឆ្នាំមនុស្ស[៧]) ដោយដាំក្បាលទៅមុន។ បណ្ដាសានេះគឺមានលក្ខណៈពិសេស ហើយធ្លាប់ប្រើប្រាស់ច្រើននៅក្នុងគំនិតរបស់អ្នកស្រុកឥណ្ឌា។ គេដាក់បណ្ដាសាឲ្យអ្នកធ្វើអំពើអាក្រក់ ឬបំផ្លាញបុណ្យធ្លាក់ទៅនរកកាលសូត្រ (ខ្សែបន្ទាត់ខ្មៅ ដែលមានរយៈពេល១០០០ឆ្នាំនរក ដែលមួយថ្ងៃមួយយប់ស្មើនឹង ១២ ៩៦០ ០០០ ០០០ ០០០ឆ្នាំមនុស្ស[៨])ដោយដាំក្បាលចុះទៅមុនត្រូវអាចម៍ឆ្កែ)។ នៅលើចម្លាក់នរកសួគ៌ ថែវខាងត្បូងរបស់ប្រាសាទអង្គរវត្ត ក៏មានបង្ហាញសត្វឆ្កែចំនួន៦ក្បាល ដែលគេដឹងថាម្ចាស់ឆ្កែគឺតាកឹង (យមបាល)។ ឆ្កែនេះមាននាទីចាំយាមផ្លូវនរក ស្វែងរកសត្វនរក និងនាំសារផងដែរ[៩] (រូបលេខ២)។*

ចំណែកសិលាចារឹក K.៣៨៨ និយាយពីការធ្វើអំណោយបុណ្យជារបស់របរជាច្រើនដល់វណ្ណៈ៤ ហើយថាអ្នកណាដែលដកហូតទ្រព្យ ឬបំផ្លាញបុណ្យនេះចុះទៅនរកជាមួយញាតិការទាំង៧សន្ដាន ក្នុងនោះមាននរកជាន់ទី៣ដ៏គួរឲ្យភ័យខ្លាច (វៃតរណីទី គឺស្ទឹងវៃតរណី) ជាន់ទី៤ដែលសាហាវឃោរឃៅ (កូដសលមលី គឺ នរកព្រៃរកាដែលមានបន្លា) ទី៦ (និរបធ្វាស គឺនរកដែលគ្មានដណ្ដើម) ទី៧ (ឧបធ្វាស គឺនរកដកដង្ហើមធំ) ជាន់ទី១០ (អស្ថិភង្គ គឺនរកបំបែកឆ្អឹង) និងនរកផ្សេងៗទៀត (រូបលេខ៣)។[១០]

ក្នុងចំណោមបណ្ដាសាជាច្រើនទម្រង់ មានបណ្ដាសាមួយដែលបានប្រើជាញឹកញាប់ ហើយកំរិតទោសក៏ធ្ងន់ធ្ងរ។ ឧទាហរណ៍សិលាចារឹកប្រាសាទភ្នំសណ្ដក K.១៩៥ ផ្នែក C បានដាក់បណ្ដាសាដល់អ្នកដែលមិនធ្វើតាមបន្ទូលព្រះមហាក្សត្រ ឲ្យធ្លាក់ទៅនរកជាមួយញាតិសណ្ដានចំនួន១០០០កំណើត រហូតដល់ព្រះច័ន្ទ និងព្រះអាទិត្យលែងមាន

---

[៦] Coèdes Geoge (1973:29)

[៧] Coèdes Geoge (1973:30)

[៨] Ibit

[៩] RENOU Louis et FILLIOZART Jean (2005:335)

[១០] រ៉ា អ៊ីណារិទ្ធ (២០០២:២៥-២៩)

ទើបអាចរួចទុក្ខទោសនោះបាន។ បណ្ដាសាបែបនេះ មានកំរិតធ្ងន់ធ្ងរណាស់ អ្នកណាក្រុមណាដែលត្រូវបណ្ដាសារបៀបនេះហើយ សេចក្ដីសង្ឃឹមថានឹងរួចទោសនោះសឹងតែគ្មានឡើយ។

នៅសម័យកណ្ដាល ពាក្យបណ្ដាសាក៏មានច្រើនបែបច្រើនទម្រង់ដូចសម័យមុនអង្គរ និងសម័យអង្គរដែរ ប៉ុន្តែជាទម្រង់បែបព្រះពុទ្ធសាសា។ ឧទាហរណ៍សិលាចារឹកអង្គរវត្តលេខ៤ និយាយពីការកសាងព្រះពុទ្ធ អំពីមាស ប្រាក់ ការសង់ចេតីយ និងប្រោសខ្ញុំ។ គេដាក់បណ្ដាសាថា អ្នកដែលធ្វើឲ្យអន្តរាយទាននេះ អ្នកទាំងអំបាលនោះនឹងធ្លាក់ទៅចតុរាបាយភូមិ ចុះមហាអវចីនរក កុំបីឲ្យព្រះពុទ្ធដែលបានត្រាស់ដូចជាគ្រាប់ខ្សាច់ប្រោសអ្នកនោះបានឡើយៗ[១១] ចំណែកសិលាចារឹកលេខ២១ និយាយពីការធ្វើបុណ្យ ហើយប្រោសខ្ញុំ បានបញ្ជាក់ថា អ្នកដែលមកជំទាស់ទទែងធ្វើឲ្យខូចបុណ្យ ឲ្យរន្ទះទាំងអនន្ទបក្រវាឡ កុំបីបាញ់ដើមឈើឡើយ ឲ្យបាញ់តែអ្នកនោះសព្វៗជាតិកំណើត។ ពុំនោះសោតឲ្យទៅសោយទុក្ខវេទនានៅនាបញ្ចានន្ទរិកអស់កាលដ៏យូរលង់ ទៀតសោតព្រះពុទ្ធត្រាស់ដូចជាគ្រាប់ខ្សាច់កុំប្រោសអ្នកនោះបានឡើយ។

សរុបមក បណ្ដាសាជាពាក្យបន្ទាចដោយយកសាសនាជាគោល។ ជាពាក្យដែលដូនតាខ្មែរសំបូងសង្រួងឡើងដាក់ទោសដល់ជនទាំងឡាយណាដែលធ្វើឱ្យខូចខាត វិនាសអន្តរាយ ដល់បុណ្យ ឬសមិទ្ធផលដែលដូនតាបានកសាងឡើងដោយសេចក្ដីជ្រះថ្លា។ ជាសណ្ដាប់ ឬធម៌ដែលបានបង្កើតឡើងសម្រាប់មនុស្ស និងសង្គមទាំងមូល។[១២] ការបំផ្លាញកេរ្តិ៍ដូនតានឹងត្រូវបណ្ដាសាធ្លាក់នរកដ៏ឈឺចាប់អស់កល្បជានិច្ច និងមិនអាចស្រោចស្រង់បាន ដូច្នេះនរជនគួររក្សាកេរ្តិ៍ដូនតាឱ្យគង់វង្ស និងបានសោយសួគ៌ (រូបលេខ២)។

---

[១១] Chim Krasem 1958

[១២] មាស សុភាព ២០០៧: ២១

អត្ថបទដោយ៖ មាស សុភាព

# បញ្ជីរូបភាព



រូបលេខ១៖ ព្រះយមរាជ និងចិត្រាគុប្ត (ថែវខាងត្បូងប្រាសាទអង្គរវត្ត)



រូបលេខ២៖ ឆ្កែដែលចាំយាមសត្វនរក (ថែវខាងត្បូងប្រាសាទអង្គរវត្ត)

អត្ថបទដោយ៖ មាស សុភាព



រូបលេខ៣៖ បណ្ដុំនរកដែលទទួលរងទុក្ខវេទនាខ្លាំង (ថែវខាងត្បូងប្រាសាទអង្គរវត្ត)



រូបលេខ៤៖ ភាពដោយឡែករវាងសួគ៌ និងនរក (ថែវខាងត្បូងប្រាសាទអង្គរវត្ត)

# ឯកសារយោង

ជួន ណាត

១៩៦៧-១៩៦៨, *វចនានុក្រមខ្មែរ ភាគ១-២*, ភ្នំពេញ

មាស សុភាព

២០០៧, *ពរ និងបណ្ណាសាក្នុងសិលាចារឹក*, សារណាបរិញ្ញាបត្របុរាណវិទ្យា។

វ៉ា អ៊ីណារិទ្ធ

២០០៦, *ជំនឿលើឋានសួគ៌ និងឋាននរក*, សារណាបរិញ្ញាបត្របុរាណវិទ្យា។

Chim Krasem

1958, Nouvelle preface de Savaros Pou, 1984, *Inscriptions Moderns Angkor,* Paris.

Coèdes Geoge

1973, *Les Trois Mondes*, (Traubhumi Brah Rvan), LXXXXIX, Paris.

Renou Louis et Filliozat

2005, L'INDE CLASSIQUE, Payot, Paris.

Stchoupan, N. Nitti L et Renou L

1959, *Dictionaire Sanskrit-Françias,* Paris